**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១២៦ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៨

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១..**

អនុក្រឹត្យនេះមានគោលដៅកំណត់ អំពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គ្រូបង្រៀន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨..**

គ្រូបង្រៀនប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ ។

គ្រូបង្រៀនមានករណីយកិច្ចរៀបចំកិច្ចតែងការបង្រៀន និងកំណត់ការពន្យល់សំដៅធានាគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន ។

**មាត្រា៩..**

គ្រូបង្រៀនត្រូវស្វ័យសិក្សា និងស្រាវជ្រាវសម្រិតសម្រាំង បង្កើនចំណេះដឹងរបស់ខ្លួន និងចូលរួមក្នុងគ្រប់សកម្មភាពបណ្តុះបណ្តាលជាប្រចាំ ។

គ្រូបង្រៀនត្រូវធ្វើការស្វ័យវាយតម្លៃ និងវាយតម្លៃលើការប្រតិបត្តិវិជ្ជាជីវៈបង្រៀន ។

**មាត្រា១០..**

គ្រូបង្រៀនមានករណីយកិច្ចគាំទ្រគ្រប់សកម្មភាពអប់រំ និងសេវាអប់រំ របស់អាជ្ញាធរអប់រំគ្រប់លំដាប់ថ្នាក់ទាំងអស់ ។

**មាត្រា១១..**

គ្រូបង្រៀនត្រូវនិយាយស្តីដោយប្រុងប្រយ័ត្ន និងគិតទៅដល់ប្រតិឃាតនៃពាក្យសម្តីរបស់ខ្លួនចំពោះអ្នកសិក្សា និងសាធារណជនក្នុងការផ្តល់ព័ត៌មានអំពីការអប់រំ ទាំងសាធារណៈ ទាំងឯកជន តាមគ្រប់មធ្យោបាយផ្សព្វផ្សាយ ។

គ្រូបង្រៀនមិនត្រូវធ្វើប្រជាភិថុតិចំពោះអ្នកសិក្សាឡើយ ។

គ្រូបង្រៀនមិនត្រូវផ្សព្វផ្សាយអំពីការវិនិច្ឆ័យវិន័យរដ្ឋបាលបុគ្គល នៅក្នុងមជ្ឈដ្ឋានអប់រំ ក៏ដូចជាក្នុងមជ្ឈដ្ឋានសាធារណៈឡើយ ។

**មាត្រា១២..**

គ្រូបង្រៀនមិនត្រូវសមគំនិតតាមផ្លូវកាយ ឬ តាមផ្លូវចិត្ត ឬ សម្ភារៈ និង/ឬ តាមរយៈការផ្តល់មធ្យោបាយ ដែលធ្វើឱ្យខូចប្រយោជន៍អ្នកសិក្សាក្នុងសេវាអប់រំឡើយ ។

គ្រូបង្រៀនមិនត្រូវដាក់ទណ្ឌកម្មខាងផ្លូវកាយ និងផ្លូវចិត្តដែលនាំឱ្យមានផលប៉ះពាល់ដល់អ្នកសិក្សាទេ ។

**មាត្រា១៣..**

គ្រូបង្រៀនមិនត្រូវរៃអង្គាសប្រាក់ ឬ ប្រមូលប្រាក់ក្រៅផ្លូវការ ឬ ធ្វើអាជីវកម្មនានាក្នុងថ្នាក់រៀនឡើយ ។

គ្រូបង្រៀនត្រូវជៀសវាងការប្រកបមុខរបរផ្សេងក្នុងបរិវេណគ្រឹះស្ថានសិក្សា ។

**មាត្រា១៤..**

គ្រូបង្រៀនត្រូវជៀសវាងការប្រព្រឹត្តអំពើទាំងឡាយណា ដែលធ្វើឱ្យអាប់ឱនដល់កិត្តិយស និងវិជ្ជាជីវៈរបស់ខ្លួន ។

គ្រូបង្រៀនមិនត្រូវផ្តល់ការសម្រួលគ្រប់បែបយ៉ាង ដែលនាំឱ្យខ្លួនធ្វើខុសច្បាប់ និងបទបញ្ជាឡើយ ។

## ជំពូកទី៣

## ករណីយកិច្ចរបស់គ្រូបង្រៀនចំពោះអ្នកសិក្សា និងមាតាបិតា ឬ អ្នកអាណាព្យាបាល

**មាត្រា១៥..**

គ្រូបង្រៀនត្រូវយកចិត្តទុកដាក់ក្នុងការពន្យល់ ការបកស្រាយ និងសម្របសម្រួលដល់អ្នកសិក្សា នូវចំណេះដឹងនានាស្របតាមមុខវិជ្ជា ឬ ឯកទេសរបស់ខ្លួន។

**មាត្រា១៦..**

គ្រូបង្រៀនមានករណីយកិច្ចជួយអ្នកសិក្សា មាតាបិតា ឬ អ្នកអាណាព្យាបាលអ្នកសិក្សា ដោយមិនរើសអើង។

គ្រូបង្រៀនត្រូវជួយបង្រៀនបន្ថែមដល់អ្នកសិក្សារៀនយឺត។

**មាត្រា១៧..**

គ្រូបង្រៀនត្រូវដឹកនាំសកម្មភាពសិក្សាក្នុងថ្នាក់ និងក្រៅថ្នាក់ និងលើកទឹកចិត្តដល់អ្នកសិក្សាជាប់ជាប្រចាំ។

គ្រូបង្រៀនមានករណីយកិច្ចបង្រៀន ដោយមិនត្រូវដាក់សម្ពាធយកជាប្រយោជន៍លើអ្នកសិក្សាឡើយ។

**មាត្រា១៨..**

គ្រូបង្រៀនត្រូវជួយសម្រួលដល់អ្នកសិក្សា ក្នុងការទទួលបាននូវផលប្រយោជន៍សង្គម ដោយមិនលម្អៀង និងមានទំនាក់ទំនងជាមួយមាតាបិតា ឬ អ្នកអាណាព្យាបាលរបស់អ្នកសិក្សា ដើម្បីតាមដានលើរាល់សកម្មភាពសិក្សា។

**មាត្រា១៩..**

គ្រូបង្រៀនមិនត្រូវប្រព្រឹត្តសកម្មភាពខុសច្បាប់ ដែលនាំឱ្យមានការប៉ះពាល់ដល់ការបង្រៀន និងការរៀន និងការប្រឡងរបស់អ្នកសិក្សាឡើយ។

## ជំពូកទី៤

## ទំនាក់ទំនងរវាងគ្រូបង្រៀន និងគ្រូបង្រៀន និងជាមួយបុគ្គលិកមិនបង្រៀន

**មាត្រា២០..**

គ្រូបង្រៀនត្រូវរក្សាទំនាក់ទំនងជាសហភាតរៈ ដើម្បីជាគំរូដល់អ្នកសិក្សា និងរក្សាកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់គ្រូបង្រៀនឱ្យបានល្អ។

**មាត្រា២១..**

គ្រូបង្រៀនមិនត្រូវបង្កទំនាស់រវាងគ្រូបង្រៀន និងគ្រូបង្រៀន រវាងគ្រូបង្រៀន និងបុគ្គលិកមិនបង្រៀន។ ក្នុងករណីមានទំនាស់គ្រូបង្រៀនត្រូវចេះសម្រុះសម្រួលគ្នាក្នុងស្មារតីសាមគ្គីភាព ។

**មាត្រា២២..**

គ្រូបង្រៀនត្រូវជួយគ្នាទៅវិញទៅមក និងសហការគ្នាផ្លាស់ប្តូរបទពិសោធក្នុងការបង្រៀន ។

គ្រូបង្រៀនអាចបង្រៀនជំនួសគ្នាបានក្នុងករណីចាំបាច់ ដោយមានការអនុញ្ញាតពីប្រធានក្រុមបច្ចេកទេស និងប្រធានអង្គភាព ។

**មាត្រា២៣..**

គ្រូបង្រៀនត្រូវមានទំនាក់ទំនងល្អជាមួយបុគ្គលិកមិនបង្រៀន និងគោរពឋានានុក្រមគ្រប់គ្រងតាមលំដាប់ថ្នាក់ ។

## ជំពូកទី៥
## អំពីការប្រកបវិជ្ជាជីវៈ

**មាត្រា២៤..**

គ្រូបង្រៀនមិនត្រូវធ្វើឱ្យប៉ះពាល់ ឬ ខូចខាតដល់គុណភាពអប់រំក្នុងការបំពេញការងារ ទោះបីតាមរូបភាពណាក៏ដោយ ។

**មាត្រា២៥..**

គ្រូបង្រៀននៅគ្រឹះស្ថានសាធារណៈមានសិទ្ធិបង្រៀនជាលក្ខណៈឯកជនក្រៅម៉ោងធ្វើការ ។

**មាត្រា២៦..**

គ្រូបង្រៀនមិនត្រូវធ្វើឱ្យបាត់បង់មនសិការវិជ្ជាជីវៈក្នុងការបំពេញករណីយកិច្ច និងកាតព្វកិច្ចរបស់ខ្លួនឡើយក្នុងការប្រកបវិជ្ជាជីវៈបង្រៀន ក្រោមកិច្ចសន្យា ឬ លក្ខន្តិកៈជាមួយស្ថាប័នសាធារណៈ ឬ ស្ថាប័នឯកជន ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ។

គ្រូបង្រៀនត្រូវខិតខំបំពេញការងារ ដោយផ្តល់អាទិភាពទៅលើផលប្រយោជន៍របស់អ្នកសិក្សា និងផលប្រយោជន៍សាធារណៈ ។

**មាត្រា២៧..**

គ្រូបង្រៀនដែលប្រកបវិជ្ជាជីវៈបង្រៀន នៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ឬ គ្រឹះស្ថានសិក្សាឯកជន មិនត្រូវប្រើប្រាស់មុខងារជាគ្រូបង្រៀនបង្ខំឱ្យអ្នកសិក្សាមកសិក្សាជាមួយខ្លួន ឬ គ្រូបង្រៀនផ្សេងទៀតឡើយ ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា២៨.-**

គ្រូបង្រៀនត្រូវគោរពតាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀននេះ ។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំបែបបទ និងនីតិវិធីនៃការអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ។

**មាត្រា២៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ